# ព្រះរាជក្រម

នស/រកម/១២១៥/ ០១៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហាគាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៥ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់
# ស្តីពី
# ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង
# ឆ្នាំ ២០១៦

# ជំពូកទី ១
## ថវិកាថ្នាក់ជាតិ

**មាត្រា ១.-**

ត្រូវបានអនុញ្ញាតសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ឲ្យប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិ នូវពន្ធដារ វិភាគទាន អាករ ផលទុន និងចំណូលនានា ព្រមទាំងធ្វើឲ្យសម្រេចនូវឧបត្ថម្ភធនវិនិយោគ និងការខ្ចីតាមមាតិកាថវិកា ដូចមានចែងក្នុងតារាង "ក១" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន ១៧ ៦១២ ៤៧៧ លាន រៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណូលចរន្ត.......................................................១៣ ៤០៧ ២៦៣ លាន រៀល
- ចំណូលមូលធន....................................................៤ ២០៥ ២១៤ លាន រៀល
  - \+ ចំណូលមូលធនក្នុងប្រទេស...............................១៣០ ៨៦៤ លាន រៀល
  - \+ ចំណូលមូលធនក្រៅប្រទេស...........................៤ ០៧៤ ៣៥០ លាន រៀល
    - មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ ........................................................២០៣ ០០០ លាន រៀល
    - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ........................................................ ៣ ៨៧១ ៣៥០ លាន រៀល ។

**មាត្រា ២.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ត្រូវបានកំណត់ស្មើនឹង ១៧ ៤៦២ ៤៧៧ លាន រៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណាយចរន្ត.....................................................១១ ១៥៦ ៩៨៩ លាន រៀល
- ចំណាយមូលធន...................................................៦ ៣០៥ ៤៨៨ លាន រៀល

ក- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

...............................................................១ ៩២៥ ០០០ លាន រៀល

- ដោយថវិកាថ្នាក់ជាតិ..............................១ ៦៧៥ ០០០ លាន រៀល
  - គម្រោងវិនិយោគផ្ទាល់...............១ ២២៤ ០០០ លាន រៀល
  - បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស ..............................................៤៥១ ០០០ លាន រៀល

- ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ

..........................................................២៥០ ០០០ លាន រៀល

ខ- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

..........................................................៣ ៨៧១ ៣៥០ លាន រៀល

គ- ការទូទាត់ការខ្ចី.................................................. ៥០៩ ១៣៨ លាន រៀល ។

**មាត្រា ៣.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយចរន្តថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ត្រូវបានកំណត់ស្មើនឹង ១១ ១៥៦ ៩៨៩ លាន រៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទចំណាយ ដូចមានចែងក្នុងតារាង "**ខ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៤.-**

ចំនួនទឹកប្រាក់នៃឥណទានចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស សម្រាប់ការគ្រប់គ្រងពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៨ ត្រូវបានកំណត់ស្មើនឹង ១៦ ៨៤២ ១៨២ លាន រៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ តាមគម្រោង និងតាមឆ្នាំ ដូចមានចែងក្នុងតារាង "**គ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៥.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សម្រាប់ចំណាយ មូលធនថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ត្រូវបានកំណត់ដូចខាងក្រោម ៖

- ឥណទានភ្ជាប់សន្យា................................៦ ៣០៥ ៤៨៨ លាន រៀល
- ឥណទានទូទាត់..................................... ៦ ៣០៥ ៤៨៨ លាន រៀល ។

ឥណទាននេះត្រូវបានបែងចែកដូចតទៅ ៖

ក. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

- ឥណទានភ្ជាប់សន្យា............................... ១ ៩២៥ ០០០ លាន រៀល
- ឥណទានទូទាត់.................................... ១ ៩២៥ ០០០ លាន រៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

- ឥណទានភ្ជាប់សន្យា...............................៣ ៨៧១ ៣៥០ លាន រៀល

- ឥណទានទូទាត់....................................៣ ៨៧១ ៣៥០ លាន រៀល

គ. ការទូទាត់ការខ្ចី

- ឥណទានភ្ជាប់សន្យា.................................. ៥០៩ ១៣៨ លាន រៀល
- ឥណទានទូទាត់....................................... ៥០៩ ១៣៨ លាន រៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ ដូចមានចែងក្នុងតារាង "**គ២**" និង "**ឃ**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៦.-**

តុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ដែលបានរៀបចំនៅក្នុងតារាង "**ក១**" ស្តីពីចំណូលថវិកាថ្នាក់ជាតិ និងតារាង "**ខ១**" ស្តីពីចំណាយថវិកាថ្នាក់ជាតិ ត្រូវបានបង្ហាញនៅក្នុងតារាងកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិដូចខាងក្រោម ៖

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ | ចំនួនទឹកប្រាក់ | តុល្យភាព/ ហិរញ្ញប្បទាន |
|---|---|---|
| I. ចំណូលក្នុងប្រទេសសរុប | ១៣ ៥៣៨ ១២៧ | |
| ១. ចំណូលចរន្ត | ១៣ ៤០៧ ២៦៣ | |
| ២. ចំណូលមូលធនក្នុងប្រទេស | ១៣០ ៨៦៤ | |
| II. ចំណាយថវិកាសរុប | ១៦ ៩៥៣ ៣៣៩ | |
| ១. ចំណាយចរន្ត | ១១ ១៥៦ ៩៨៩ | |
| ២. ចំណាយមូលធន (មិនគិតការទូទាត់ការខ្ចី) | ៥ ៧៩៦ ៣៥០ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ១ ៩២៥ ០០០ | |
| + ដោយថវិកាថ្នាក់ជាតិ | ១ ៦៧៥ ០០០ | |
| - គម្រោងវិនិយោគផ្ទាល់ | ១ ២២៤ ០០០ | |
| - បដិភាគ | ៤៥១ ០០០ | |
| + ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទាន ដោយដៃគូអភិវឌ្ឍ | ២៥០ ០០០ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ៣ ៨៧១ ៣៥០ | |
| អតិរេកនៃថវិកាចរន្ត ( I.១ -II.១ ) | | +២ ២៥០ ២៧៤ |
| ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ ( I-II ) | | -៣ ៤១៥ ២១២ |
| III. ហិរញ្ញប្បទាននៃឱនភាព | | +៣ ៤១៥ ២១២ |
| ១. ហិរញ្ញប្បទានក្រៅប្រទេស | | +៣ ៥៦៥ ២១២ |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | | +២០៣ ០០០ |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | +៣ ៨៧១ ៣៥០ |
| • ការទូទាត់ការខ្ចី | | -៥០៩ ១៣៨ |
| ២. ហិរញ្ញប្បទានក្នុងប្រទេស | | -១៥០ ០០០ |
| • បញ្ញើរាជរដ្ឋាភិបាល | | -១៩៧ ០០០ |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | | +៤៧ ០០០ |

# ជំពូកទី ២

## ការខ្ចី និងការធានារបស់រដ្ឋ

**មាត្រា ៧.-**

សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ អនុម័តយល់ព្រមឲ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេក្នុងកម្រិត ៧00 000 000 SDR (ប្រាំពីររយលានអេសដេអ៊ែរ) ។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកម្រិតខាងលើ ត្រូវមានលក្ខណៈជាការខ្ចីសម្បទានដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ ។

នៅក្នុងលក្ខខណ្ឌនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់ តាមការប្រទានសិទ្ធិជាលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងការចុះហត្ថលេខាលើការខ្ចី ជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬលើការធានារបស់រដ្ឋ ហើយត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តនៃការខ្ចីនិងការធានានេះ ជូនរដ្ឋសភា និងព្រឹទ្ធសភារៀងរាល់ ៦ ខែម្តង ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការឯកភាពពីធនាគារជាតិនៃកម្ពុជា ត្រូវបានទទួលការអនុញ្ញាតឲ្យបោះផ្សាយបណ្ណរតនាគារ ក្នុងកម្រិតទឹកប្រាក់ដែលមានស្តុកចំនួន ១00 000 000 000 រៀល(មួយរយប៊ីលានរៀល) ដើម្បីដោះស្រាយតម្រូវការជាបន្ទាន់ខាងសាច់ប្រាក់ ។ លក្ខខណ្ឌនៃការលក់បណ្ណរតនាគារនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានស្របច្បាប់ ។

**មាត្រា ៩.-**

មិនអនុញ្ញាតឲ្យក្រសួង ឬស្ថាប័នសាធារណៈណាមួយចំណុះរដ្ឋ មានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលបត្ររយៈពេលវែង មធ្យម ខ្លី ឬឥណទានអ្នកផ្គត់ផ្គង់ ឬចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬការធានាកិច្ចសន្យា ដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈ ឬឯកជន ឬចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសងបំណុលតាមកាលកំណត់ ឬតាមឆ្នាំ ដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុ និងលក្ខខណ្ឌទាំងឡាយដែលច្បាប់នេះបានកំណត់នោះទេ ។

ROYAUME DU CAMBODGE · LE CABINET ROYAL · PALAIS ROYAL

# ជំពូកទី ៣
## បទប្បញ្ញត្តិស្តីពីពន្ធដារ

**មាត្រា ១០.-**

មាត្រា ៤ នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ត្រូវបានកែប្រែដូចខាងក្រោម ៖

មាត្រា ៤.- ថ្មី

របបកំណត់ពន្ធនៃព្រះរាជាណាចក្រកម្ពុជាជារបបស្វ័យប្រកាស ដែលតម្រូវឲ្យអ្នកជាប់ពន្ធធ្វើការគណនាប្រាក់ពន្ធ និងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធដោយខ្លួនឯង ។ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវបានចែកជាបីប្រភេទគឺ អ្នកជាប់ពន្ធតូច អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ ។

វិធាននិងនីតិវិធី ធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមប្រភេទនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើទ្រង់ទ្រាយអាជីវកម្ម និងកម្រិតផលរបរ ។

**មាត្រា ១១.-**

មាត្រា ៦ នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ១៩៩៧ ត្រូវបានកែប្រែដូចខាងក្រោម ៖

មាត្រា ៦.- ថ្មី

វិធានគណនេយ្យត្រូវបានកំណត់ដូចខាងក្រោម ៖

អ្នកជាប់ពន្ធតូច ត្រូវប្រើវិធានគណនេយ្យសាមញ្ញ ដែលនឹងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ ត្រូវប្រើវិធានគណនេយ្យតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ។ ប្រាក់ចំណូលត្រូវគិតបញ្ចូលនៅក្នុងឆ្នាំដែលចំណូលនោះបានកើតឡើង ទោះបីប្រាក់ចំណូលនោះបានទូទាត់ ឬមិនទាន់ទូទាត់ក្តី ។ ការកាត់កងចំណាយណាមួយអាចធ្វើទៅបាន លុះណាតែហេតុការណ៍បញ្ជាក់នូវបន្ទុករបស់អ្នកជាប់ពន្ធបានកើតឡើង លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលជាប់ទាក់ទងដល់ខ្ទង់ចំណាយនោះបានកើតឡើង និងចំនួនទឹកប្រាក់ដែលជាបន្ទុករបស់អ្នកជាប់ពន្ធអាចបង្ហាញច្បាស់លាស់ ។

ចំណាយនានាធ្វើឡើងចំពោះបុគ្គលទាក់ទិន ដែលមិនស្ថិតក្រោមរបបស្វ័យប្រកាសមិនអនុញ្ញាតឲ្យកាត់កងមុនការទូទាត់ជាក់ស្តែងឡើយ ។

ធនាគារ ស្ថាប័នសញ្ញ័យធន និងស្ថាប័នឥណទានក្នុងស្រុកត្រូវបានអនុញ្ញាតឲ្យធ្វើសំវិធានធនសម្រាប់ឥណទេយ្យជាប់សង្ស័យដើម្បីកំណត់ប្រាក់ចំណេញជាប់ពន្ធ ។ វិធាន និងនីតិវិធីស្តីពីការកាត់កងនានា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## មាត្រា ១២.-

ចំនួនប្រាក់ពន្ធប៉ាតង់ដែលបានចែងក្នុងមាត្រា ៣៩ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤ ត្រូវបានកែប្រែដូចតទៅ ៖

ប្រាក់ពន្ធប៉ាតង់ត្រូវបានកំណត់ដោយផ្អែកលើប្រភេទអ្នកជាប់ពន្ធដូចខាងក្រោម ៖

ក. អ្នកជាប់ពន្ធតូច ត្រូវបង់ប្រាក់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៤០០ ០០០ រៀល (បួនរយពាន់រៀល)

ខ. អ្នកជាប់ពន្ធមធ្យម ត្រូវបង់ប្រាក់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ១ ២០០ ០០០ រៀល (មួយលានពីរយពាន់រៀល)

គ. អ្នកជាប់ពន្ធធំ ត្រូវបង់ប្រាក់ពន្ធប៉ាតង់ប្រចាំឆ្នាំជាអប្បបរមាចំនួន ៣ ០០០ ០០០ រៀល (បីលានរៀល) និងជាអតិបរមាចំនួន ៥ ០០០ ០០០ រៀល (ប្រាំលានរៀល) ។

ពន្ធប៉ាតង់ត្រូវបានកំណត់លើសកម្មភាពអាជីវកម្មនីមួយៗរបស់អ្នកជាប់ពន្ធ ។ សកម្មភាពជាឧបសម្ព័ន្ធនានានៃសកម្មភាពអាជីវកម្មត្រូវបានចាត់ទុកថាជាសកម្មភាពអាជីវកម្មតែមួយ ។ អ្នកជាប់ពន្ធដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់មុខរបរអាជីវកម្មតែមួយនៅក្នុងរាជធានី ខេត្តតែមួយ ត្រូវបង់ពន្ធប៉ាតង់តែមួយ ។

វិធាន និងនីតិវិធីអនុវត្តការបង់ពន្ធប៉ាតង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## មាត្រា ១៣.-

ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទដែលបានកំណត់ដោយមាត្រា ១៤ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០១៩៨/០០១ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៨ និងមាត្រា ១១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១១៣/០១៥ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ត្រូវបានកែសម្រួលនិងកំណត់ដូចខាងក្រោមនេះ ៖

ស្មុំប្រចាលការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទចំពោះ ៖

ក. ទោចក្រយានយន្ត និងត្រីចក្រយានយន្តគ្រប់ប្រភេទ

ខ. ត្រាក់ទ័រ និងគ្រឿងយន្តប្រហាក់ប្រហែល

គ. ជលយានយន្តគ្រប់ប្រភេទ ដែលមានកម្លាំងដល់ ១៥០ សេះ ។

កែសម្រួល និងកំណត់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទចំពោះមធ្យោបាយដឹកជញ្ជូនដូចក្នុងតារាងខាងក្រោម ៖

ឯកតា៖ រៀល

| **ប្រភេទមធ្យោបាយដឹកជញ្ជូន និងយានជំនិះ** | **កម្រិតប្រាក់ពន្ធសម្រាប់ ១ ឆ្នាំ ក្នុងមួយគ្រឿង** |
|---|---|
| រថយន្តដឹកទំនិញមានទម្ងន់សរុប [ទម្ងន់រថយន្ត និងទម្ងន់ផ្ទុក (ទំនិញនិងមនុស្ស)] ៖ | |
| ក- ដល់ ៣តោន | ២០០ ០០០ |
| ខ- លើសពី ៣តោន ដល់ ១០តោន | ៥០០ ០០០ |
| គ- លើសពី ១០តោន ដល់ ២០តោន | ១ ០០០ ០០០ |
| ឃ- លើសពី ២០តោន | ២ ០០០ ០០០ |
| រ៉ឺម៉កសណ្ដោងដែលមានទម្ងន់សរុប (ទម្ងន់រ៉ឺម៉ក និងទម្ងន់ផ្ទុក) ៖ | |
| ក- ចាប់ពី ៣តោន ដល់ ១០តោន | ៥០០ ០០០ |
| ខ- លើសពី ១០តោន ដល់ ២០តោន | ១ ០០០ ០០០ |
| គ- លើសពី ២០តោន | ២ ០០០ ០០០ |

ចំពោះប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះដទៃទៀត ត្រូវបានរក្សាទុកដដែល ។

វិធាន និងនីតិវិធីលម្អិតសម្រាប់គ្រប់គ្រងប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

# ជំពូកទី ៤

## ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា ១៤.-**

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា ៨៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ និងបទប្បញ្ញត្តិនៃមាត្រា ៣៥ និងមាត្រា ៥៤ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ ចំណូល-ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ សរុបចំនួន ១ ៣៣៤ ៥២៥ លាន រៀល ត្រូវបានកំណត់ដូចខាងក្រោមនេះ ៖

**ក.ថវិការបស់រដ្ឋបាលរាជធានី ខេត្ត**

- ចំណូលថវិកាសរុប.....................................៩១៤ ៦៣៥ លាន រៀល
  - +ចំណូលចរន្តសរុប....................................៨០៨ ៨៩៤ លាន រៀល
    - -ចំណូលសារពើពន្ធ.............................៧៧៧ ៥០៤ លាន រៀល
    - -ចំណូលមិនមែនសារពើពន្ធ.....................៣១ ៣៩០ លាន រៀល
  - +ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ.................. ១០៥ ៧៤១ លាន រៀល ។
- ចំណាយថវិកាសរុប.....................................៩១៤ ៦៣៥ លាន រៀល
  - +ចំណាយចរន្ត............................................៦៨០ ៧៣០ លាន រៀល
  - +ចំណាយមូលធន........................................១៥២ ៩០៥ លាន រៀល
  - +អតិរេករាជធានី ខេត្ត....................................៨១ ០០០ លាន រៀល ។

ចំណូលរបស់រដ្ឋបាលរាជធានី ខេត្ត តាមមាតិកាថវិកា ត្រូវបានកំណត់ដូចមានចែងក្នុងតារាង "**ក២**" និងឥណទានចំណាយបែងចែកទៅតាមរដ្ឋបាលរាជធានី ខេត្តនីមួយៗនិងទៅតាមប្រភេទចំណាយ ត្រូវបានកំណត់ដូចមានចែងក្នុងតារាង "**ខ២**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**ខ.ថវិការបស់រដ្ឋបាលក្រុង ស្រុក**

- ចំណូលថវិកាសរុប.......................................១១១ ៤៨០ លាន រៀល

  +ចំណូលចរន្តសរុប......................................... ១២ ៣៤៨ លាន រៀល

  -ចំណូលមិនមែនសារពើពន្ធ......................១២ ៣៤៨ លាន រៀល

  +ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ...................... ៩៩ ១៣២ លាន រៀល ។

- ចំណាយថវិកាសរុប....................................... ១១១ ៤៨០ លាន រៀល

  +ចំណាយចរន្ត.............................................. ១១១ ៤៨០ លាន រៀល ។

**គ.ថវិការបស់រដ្ឋបាលឃុំ សង្កាត់**

- ចំណូលថវិកាសរុប....................................... ៣០៨ ៤១០ លាន រៀល

  +ចំណូលឧបត្ថម្ភពីថវិកាជាតិសរុប.....................៣០៨ ៤១០ លាន រៀល

  -ចំណូលសង្កាត់ចំណុះរាជធានី......................២០ ៦១១,២ លាន រៀល

  -ចំណូលសង្កាត់ចំណុះក្រុង.........................២៤ ៣៧៦,២ លាន រៀល

  -ចំណូលឃុំ.............................................២៦៣ ៤២២,៦ លាន រៀល ។

- ចំណាយថវិកាសរុប.......................................៣០៨ ៤១០ លាន រៀល

  +ចំណាយសរុប..............................................៣០៨ ៤១០ លាន រៀល

  -ចំណាយសង្កាត់ចំណុះរាជធានី.................២០ ៦១១,២ លាន រៀល

  -ចំណាយសង្កាត់ចំណុះក្រុង......................២៤ ៣៧៦,២ លាន រៀល

  -ចំណាយឃុំ.................................២៦៣ ៤២២,៦ លាន រៀល ។

ការបែងចែកកញ្ចប់ថវិការួមនេះទៅតាមរាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់នីមួយៗក៏ដូចជាការបែងចែកឥណទាននៅផ្ទៃក្នុងថវិកាជាជំពូក គណនី និងអនុគណនី ត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ ។

ROYAUME DU CAMBODGE • LE MINISTERE DU PALAIS ROYAL

# ជំពូកទី៥

# អវសានប្បញ្ញត្តិ

**មាត្រា ១៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៦.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៥

នស/រកម.០៦១៥.០១៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ហត្ថលេខា**
**អូន ព័ន្ធមុនីរ័ត្ន**

លេខ: ១១៤៤ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ មិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**